# សវនាការភស្តុតាងលើអង្គសេចក្តីក្នុងសំណុំរឿង០០២ : សាក្សី ប្រាក់ យុត ធ្វើសក្ខីកម្មបន្ត

*វ៉េនឌុល ឌីហ្សាល់កូ*

*ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២*

*ប្រែសម្រួលដោយ ផា ផល្លា*

*«ខ្ញុំមិនហ៊ានប្រាប់គាត់ទេ»*

*-សាក្សី ប្រាក់ យុត និយាយសំអាងទៅលើអ្វីដែលគាត់ដឹងមុនថា ប្តីរបស់គាត់នឹងត្រូវចាប់ខ្លួន*

ក្រោយពីរយៈពេលប្រាំមួយថ្ងៃកន្លះនៃបញ្ហាដាក់បញ្ចូលភស្តុតាង អង្គជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមសវនាការលើភស្តុតាងសម្រាប់ករណី០០២ នៅថ្ងៃទី២៦ មករា ឆ្នាំ២០១២នេះទៀត ។ ពេញមួយថ្ងៃនៃដំណើរការសវនាការនេះ សាក្សី ប្រាក់ យុត បានធ្វើសក្ខីកម្មបន្តពីរសៀលម្សិលមិញ ។

## ការមិនយល់ស្របទាក់ទងនឹងដែនកំណត់នៃការសួរសំណួរ

អង្គជំនុំជម្រះចាប់ផ្តើមនៅថ្ងៃនេះដោយសួរទៅគ្រប់ភាគីទាំងអស់ថា តើមានលើកពីបញ្ហាអ្វីទេ? មេធាវី ខាណាវ៉ាស របស់ អៀង សារី បានក្រោកឡើង និងបកស្រាយពីចំណាត់ការរបស់អង្គជំនុំជម្រះ ។ មេធាវី ខាណាវ៉ាស បានជំទាស់ទៅនឹងដែនកំណត់នៃការសួរសំណួរដោយព្រះរាជអាជ្ញាកាលពីម្សិលមិញដែលបានសួរសំណួរប្រាស់ចាកពីដែនកំណត់ក្នុងការសួរទាក់ទងទៅនឹងករណី០០២ក្នុងដំណាក់កាលដំបូងនេះ ។ មេធាវីបានបញ្ជាក់ថា អង្គជំនុំជម្រះធ្លាប់បញ្ជាក់កាលពីមុនថា សំណួរដែលប្រាស់ចាកពីប្រធានបទអាចចោទសួរបាន លុះតែព្រះរាជអាជ្ញាត្រូវធ្វើពាក្យសុំជាមុនសិន មុននឹងចាប់សួរពីប្រធានបទដែលមិនពាក់ព័ន្ធនេះ ហើយអង្គជំនុំជម្រះធ្លាប់បានជម្រាបហើយថា ពាក្យសុំនេះ «កម្រនឹងអនុញ្ញាតឲ្យណាស់» ។

មេធាវី ខាណាវ៉ាស បានអះអាងបន្ថែមទៀតថា អង្គជម្រះ«ដឹងច្បាស់ក្រឡែត»ថា ប្រធានបទទាំងអស់នេះនឹងយកមកចោទសួរអំឡុងពេលនៃការសួរសំណួរនេះ ហើយព្រះរាជអាជ្ញាមិនបានធ្វើតាមការណែនាំរបស់អង្គជំនុំជម្រះទេក្នុងអំឡុងពេលនៃការសួរសំណួរទៅកាន់សាក្សី ប្រាក់ យុត កាលពីម្សិលមិញ ។ មេធាវី ខាណាវ៉ាស បានលើកពីឧទាហរណ៍មួយ អំពីការសួរអំពីការធ្វើទំនប់ដោយរបប

កម្ពុជាប្រជាធិបតេយ្យ ហើយមេធាវីរូបនេះបានបញ្ជាក់ថា ព្រះរាជអាជ្ញាអាចព្យាយាមរកការសួរនាំពីប្រធានបទផ្សេងទៀត ដែលប្រធានបទនោះមិនត្រូវយកមកនិយាយក្នុងដំណាក់កាលដំបូងនៃករណី០០២នេះទេ បើសិនជាក្រុមការពារក្តីនៅតែជំទាស់ដដែលដាដដែលនោះ នោះក្រុមការពារក្តីនឹងទទួលនូវការចោទប្រកាន់ថា បានព្យាយាមពន្យឺតដំណើរការសួរនាំនេះជាមិនខាន ។

មេធាវី ខាណាវ៉ាស បានបញ្ចប់ការសួរនាំដោយស្នើទៅអង្គជំនុំជម្រះឲ្យណែនាំព្រះរាជអាជ្ញារក្សាសំណួររបស់ខ្លួនឲ្យចំប្រធានបទនៃដំណាក់កាលដំបូងនៃករណី០០២នេះ និងបានស្នើសុំឲ្យមានការពន្យល់ពីព្រះរាជអាជ្ញាផងដែរ ។

ព្រះរាជអាជ្ញាអន្តរជាតិ ដា លីសាក់ បានឆ្លើយតបទៅវិញថា បើសិនជាមេធាវី ខាណាវ៉ាស បានអានកឋាខណ្ឌមួយចំនួននៃដីការដំណោះស្រាយ ដែលស្រង់ពាក្យដោយព្រះរាជអាជ្ញាទាក់ទងទៅនឹងសាក្សី ប្រាក់ យុត នោះមេធាវីនឹងដឹងច្បាស់ថា សាក្ខីកម្មរបស់សាក្សីនេះ គឺទាក់ទងទៅនឹងទំនាក់ទំនងនៃរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជាអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។

ដា លីសាក់ បានអះអាងថា សាក្សីរូបនេះត្រូវបានកោះហៅដោយសារតែគាត់មានតួនាទីជាលេខាស្រុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយសក្ខីកម្មរបស់គាត់អាចជួយផ្តល់ហេតុការណ៍ពិតទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងលំហូរនៃព័ត៌មានពីលើចុះក្រោមក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ទាក់ទងទៅនឹងការជ្ឋានលើកទំនប់ ដា លីសាក់ បានបញ្ជាក់ថា សក្ខីកម្មរបស់ ប្រាក់ យុត ត្រូវបានសួរចម្រាញ់ទាក់ទងទៅនឹងប្រធានបទនេះ ព្រោះព្រះរាជអាជ្ញាចង់ដឹងអំពីព័ត៌មានទាក់ទងទៅនិងលក្ខខណ្ឌរស់នៅនោះមានសភាពយ៉ាងដូចម្តេចក្នុងរដ្ឋាភិបាលបក្សកុម្មុយនីស្តកម្ពុជា ។

ដា លីសាក់ បានបញ្ជាក់ទៀតថា ព្រះរាជអាជ្ញាមិនមានគម្រោងសួរលម្អិតអំពីបន្សុទ្ធកម្មរបស់ភូមិភាគកណ្តាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយជាប្រធានបទសំខាន់ទីពីរដែលព្រះរាជអាជ្ញាចង់សួរទៅសាក្សី ប្រាក់ យុត នោះទេ ។

ជាមួយគ្នានោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វុត បានលើកឡើងថា ទោះបីជាគាត់ យល់ស្របជាមួយមេធាវីការពារក្តីក៏ដោយ ត្រង់ថា ច្បាប់ត្រូវតែស្មើភាពគ្នាគ្រប់ភាគីទាំងអស់ តែនេះគឺជាជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីចង់បញ្ជាក់ថា អ្វីដែលព្រះរាជអាជ្ញាបានសួរគឺមិនលើសពីដែនកំណត់ដែលត្រូវសួរក្នុងដំណាក់កាលដំបូងនៃករណី០០២នេះទេ អំឡុងពេលនៃការសួរសំណួរទៅកាន់សាក្សី ប្រាក់ យុត នេះ ។

មេធាវី ខាណាវ៉ាស បានឆ្លើយតបដោយបញ្ជាក់ថា ព្រះរាជអាជ្ញាបានធ្វើសំណើ«ដ៏ឆ្លាតវៃ» របស់ខ្លួនដោយបញ្ជាក់ថា ប្រធានបទដែលត្រូវសួរគឺទាក់ទងទៅនឹងព័ត៌មានអំពីបណ្តាញទំនាក់ទំនងប៉ុណ្ណោះ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីបានបញ្ជាក់ថា ក្នុងការធ្វើដូច្នេះ ព្រះរាជអាជ្ញាមានបំណង និងអនុញ្ញាតឲ្យមេធាវីការពារក្ដីឲ្យពិភាក្សាពីប្រធានបទផ្សេងៗដូចជា របបអាហារ និងលក្ខខណ្ឌរស់នៅ យុទ្ធសាស្ត្រនេះវាមិនត្រឹមត្រូវទេ ។ មេធាវីបានបញ្ជាក់ទៀតថា ក្រុមការពារក្ដីរបស់ អៀង សារី សូមរក្សាសិទ្ធិជំទាស់សំណួរណាដែលនៅក្រៅពីដំណាក់កាលដំបូងនៃករណី០០២នេះ ។

លោក ម៉ៃឃើល ផេស្ដមែន មេធាវីអន្តរជាតិ នួន ជា បានក្រោកឡើងនិងបង្ហាញពីការគាំទ្រដល់ការអះអាងរបស់ក្រុមការពារក្ដីរបស់ អៀង សារី ។

នៅត្រង់ចំណុចនេះ ចៅក្រម ខាត់ វ្រាយត៍ បានបង្អាក់ និងចង់«បញ្ជាក់ឲ្យច្បាស់ពីទម្រង់ការនេះ» ដើម្បីឲ្យច្បាស់នៅថ្ងៃក្រោយទៀត ។ លោកស្រីចៅក្រមបានបញ្ជាក់ថា ភាគីដែលបានដាក់សំណើនេះ ដំបូង គួរតែទទួលបានចម្លើយ លុះត្រាណាភាគីនីមួយៗត្រូវបានផ្ដល់ឱកាសបញ្ជាក់ពីជំហររបស់ខ្លួន ។ លោកស្រីចៅក្រមបានបន្ថែមទៀតថា ថ្ងៃក្រោយមេធាវីការពារក្ដីនីមួយៗគួរតែបង្ហាញពីជំហររបស់ខ្លួនទាក់ទងទៅនឹងអ្វីដែលភាគីការពារក្ដីបានលើកឡើង មុនឆ្លើយតបទៅនឹងអ្វីដែលភាគីការពារក្ដីទីមួយបានអះអាង ។

ក្រោយពីពិភាក្សាគ្នាអស់មួយសន្ទុះ ចៅក្រម និល ណុន បានឡើងបញ្ជាក់ពីគំនិតរបស់អង្គជំនុំជម្រះ ។ ក្រោយពីអង្គជំនុំជម្រះផ្ដល់ការណែនាំដល់គ្រប់ភាគីទាំងអស់ ទាក់ទងទៅនិងបែបបទនៃការសួរសំនួរ ចៅក្រម និល ណុន បានបញ្ជាក់ថា "បានកំណត់ច្បាស់ណាស់"ទាក់ទងទៅនឹងប្រធានបទដែលត្រូវចោទសួរ ហើយចៅក្រមបានណែនាំទៅគ្រប់ភាគីទាំងអស់ឲ្យផ្ដោតទៅលើតែប្រធានបទតែប៉ុណ្ណោះ ហើយការសួរសំណួរត្រូវតែច្បាស់ ។ អង្គជំនុំជម្រះបានគិតពិចារណារាល់សំណួរទាំងអស់ដែលបានចោទសួរហើយនិងបន្តពិនិត្យមើលរាល់ការសួរសំណួរទាំងអស់ ។

ដើម្បីបញ្ជាក់ឲ្យច្បាស់សម្រាប់មេធាវីអន្តរជាតិ ចៅក្រម ខាត់ វ្រាយត៍ បានបកស្រាយបន្ថែមទៀតថា អង្គជំនុំជម្រះចាត់ទុកថា សំណួរដែលបានសួរមកកាន់សាក្សី ប្រាក់ យុត គឺមិនទាក់ទងទៅនឹងប្រវត្តិនៃការកកើតនៃរបបខ្មែរក្រហមដែលអង្គជំនុំជម្រះដាក់ឲ្យសួរនោះទេ ព្រោះសំណួរទាំងអស់ទាក់ទងទៅនឹងបណ្ដាញទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ចៅក្រម ខាត់ វ្រាយត៍ ក៏បានណែនាំទៅគ្រប់ភាគីទាំងអស់កុំឲ្យសួរសំណួរប្រាស់ចាកពីប្រធានបទក្នុងដំណាក់កាលដំបូងនៃករណី០០២នេះ ហើយមិនត្រូវប្រើសំណួរនាំមុខ ឬសំណួរបើកទេ ដែលការសួរបែបនេះអាចជម្រុញឲ្យសាក្សីឆ្លើយតាមអ្វីដែលបានចោទសួរ ។ ទីបញ្ចប់ លោកស្រីចៅក្រមណែនាំទៅគ្រប់ភាគីទាំងអស់ថា មិនត្រូវ«សួរប្រាស់ចាកពីដែនកំណត់នៃដំណាក់កាលដំបូងនេះទេ» ។

## ព្រះរាជអាជ្ញាបន្តសួរទៅកាន់សាក្សី ប្រាក់ យុត

ក្រោយពីទទួលការណែនាំអស់ហើយ សាក្សី ប្រាក់ យុត ចាប់ផ្ដើមធ្វើសក្ខីកម្មបន្ត។ ព្រះរាជអាជ្ញាបានសួរថា តើសាក្សីរស់នៅទីណា និងធ្វើការអ្វីខ្លះមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ សាក្សី ប្រាក់ យុត បានឆ្លើយថា គាត់មិនចាំទេថាគាត់រស់នៅទីណានៅពេលនោះ ព្រោះពេលវេលាវាកន្លងទៅយូរហើយ ។ គាត់"មិនចាប់អារម្មណ៍" ថាមាន"ប្រជាជន"ថ្មីធ្វើដំណើរមកកាន់តំបន់របស់គាត់ឬអត់ទេ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥នោះ។ គាត់មិន"ឃើញមុខអ្នកថ្មី"ទេ ហើយអ្នកដែលរស់នៅជុំវិញតំបន់ដែលគាត់រស់នៅនោះ "រស់នៅជាធម្មតា" ។ សាក្សីបន្ថែមទៀតថា ក្នុងការដាក់ឈ្មោះ "ប្រជាជន១៧ មេសា" នោះ គាត់"ក៏មិនចាប់អារម្មណ៍នឹងការហៅឈ្មោះនេះដែរ" ហើយគាត់ក៏មិនដឹងពីអត្ថន័យរបស់ពាក្យនេះដែរ ។ គាត់បានសារភាពថា គាត់"បានឮពីពាក្យប្រជាជន១៧មេសា"នេះ តែគាត់ទើបតែឮនៅអំឡុងឆ្នាំ១៩៧៦នេះទេ ។ គាត់ក៏ឮដំណឹងថា ប្រជាជនត្រូវបានជម្លៀសពីទីក្រុងដែរ ហើយគាត់សង្កេតឃើញថា មានអ្នកជម្លៀស តែគាត់"មិនចាប់អារម្មណ៍" និងកិច្ចការនោះទេ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរថា តើបទបញ្ជាក្នុងការជម្លៀសប្រជាជនពីទីក្រុងនោះមានប្រភពចេញមកពី"ថ្នាក់លើ"របស់បក្សកុម្មុយនីស្តកម្ពុជាមែនទេ? សំណួរនេះ ធ្វើឲ្យមេធាវីការពារក្ដីរបស់ អៀង សារី ជំទាស់ដោយបញ្ជាក់ថា ពាក្យ"ថ្នាក់លើ"នេះហាក់ដូចជាមិនត្រូវយកមកសួរសាក្សីនេះទេ ។ អង្គជំនុំជម្រះជំទាស់ទៅនឹងមេធាវីការពារក្ដី ហើយប្រាប់ឲ្យសាក្សីឲ្យបន្តឆ្លើយសំណួរនេះ ។

តែសាក្សី ប្រាក់ យុត ដូចជាមិនចង់ឆ្លើយសំណួរទាក់ទងទៅនឹងការជម្លៀសនេះទេ ដោយគាត់បញ្ជាក់ថា គាត់មិនចូលរួមពាក់ព័ន្ធក្នុងកិច្ចការពិភាក្សាជាមួយថ្នាក់លើទេ ។ គាត់គ្រាន់តែឃើញអ្នកជម្លៀសធ្វើដំណើរមកដោយថ្មើរជើង ដើរ"ពេញតែផ្លូវ" តែមិនដឹងច្រើនទៀតពីបញ្ហានេះទេ ហើយគាត់បានអះអាងថា អ្វីដែលគាត់និយាយនេះពិត តែ"គាត់មិនដឹងថាមានរឿងអ្វីកើតឡើងនៅថ្នាក់លើទេ" ។ នៅពេលសួរអំពីលក្ខខ័ណ្ឌរបស់អ្នកដែលត្រូវជម្លៀស ប្រាក់ យុត បានបញ្ជាក់បន្ថែមទៀតថា គាត់គិតថា ក្រុមមនុស្សទាំងនោះ "ជួបប្រទះនូវការលំបាក"ទេ ។ វាជារឿង"លំបាក"សម្រាប់មនុស្សដែល"ដើរក្រោមកំដៅថ្ងៃជាមួយកូនតូចៗ" តែគាត់មិនដឹងរឿងនេះច្រើនទៀតទេ ។

គាត់មិនដឹងទេថា ពេលនោះមានយោធាបំពាក់ដោយអាវុធនៅការពារអ្នកដែលត្រូវជម្លៀសនោះឬក៏អត់ទេ ព្រោះគាត់"មិនចាប់"អារម្មណ៍ទៅនឹងរឿងនេះទេ ហើយ"គាត់មានកិច្ចការទៀតដែលត្រូវធ្វើ" ដូចជា"ធ្វើស្រែចម្ការ"ជាដើម ។ ក្រោយមក ព្រះរាជអាជ្ញាបានសួរទៅសាក្សីបន្ថែមទៀតដើម្បីឲ្យគាត់ផ្ដល់យោបល់ថាតើអ្នកដែលត្រូចជម្លៀសនោះ មើលទៅហាក់បីដូចជាមានបំណងនឹងចង់ធ្វើដំណើរដែរឬទេ? សំណួរនេះត្រូវបានភាគីការពារក្ដី អៀង សារី ជំទាស់ដោយអះអាងថា សំណួរ

នេះមិនត្រូវសួរទៅសាក្សីទេ។ ការជំទាស់នេះត្រូវបានយល់ស្របដោយអង្គជំនុំជម្រះ ហើយព្រះរាជអាជ្ញាបន្តសួរសំណួរផ្សេងទៀត។

ព្រះរាជអាជ្ញាបានងាកទៅសួរសាក្សីកាលពីពេលដែលគាត់នៅខេត្តកំពត និងបញ្ហាទាក់ទងទៅនឹងការជម្លៀស។ ប្រាក់ យុត បានបញ្ជាក់ថា គាត់ធ្វើការនៅខេត្តកំពត តែគ្រាន់តែធ្វើការជួយលេខាស្រុកទាក់ទងទៅនឹង«កិច្ចការប្រចាំថ្ងៃ»ប៉ុណ្ណោះ ដូច្នេះគាត់មិនដឹងពីបញ្ហាជម្លៀស ឬកិច្ចការផ្សេងៗនៅតំបន់នោះទេ។ ប្រជាជនត្រូវបានជម្លៀសទៅកាន់ខេត្តកំពត ហើយសហករណ៍ត្រូវបានបង្កើតនៅទីនោះ តែគាត់មិនចាំទេថាសហករណ៍កើតឡើងនៅពេលណា ហើយនរណាជាអ្នកបញ្ជាឲ្យមានការបង្កើតសហករណ៍នេះទេ។

ត្រង់ចំណុចនេះ ដា លីសាក់ បានចូលមកសួរបន្តទៀតដោយគាត់សួរ អំពីអ្វីដែលគាត់បានផ្តល់បទសម្ភាសកាលពីលើកមុនរួចហើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប្រាក់ យុត បានបញ្ជាក់ថា អ្វីដែលគាត់បានផ្តល់បទសម្ភាសចំនួនបួនដងកាលពីលើកមុន គឺសុទ្ធតែពិតទាំងអស់ ហើយគាត់បានអះអាងបញ្ជាក់ឡើងវិញដែរ នៅអ្វីដែលគាត់ត្រូវបានសម្ភាសនោះ ត្រូវបានអានឲ្យគាត់ស្តាប់ឡើងវិញ។

ក្រោយមក ដា លីសាក់ បានចាប់សួរអំពីដំណាក់កាលដំបូងនៃការចូលក្នុងចលនាខ្មែរក្រហមក្នុងឆ្នាំ១៩៧០។ សាក្សីរូបនេះបានបញ្ជាក់ថា នៅពេលនោះ គាត់ធ្វើការនៅកំពតនិងតាកែវ។ គាត់ត្រូវបានបញ្ជូនទៅកាន់ភូមិភាគកណ្តាលក្នុងឆ្នាំ១៩៧៧។ នៅពេលសួរអំពី តាម៉ុក សាក្សីរូបនេះបានបញ្ជាក់ថា គាត់ធ្លាប់ឮឈ្មោះនេះ តែគាត់មិនស្គាល់ជិតដិតទេ។

ក្រោយមក ដា លីសាក់ បានរំឭកទៅសាក្សី ប្រាក់ យុត ថា គាត់ធ្លាប់និយាយថា បងជីដូនមួយរបស់គាត់ ហើយបានណែនាំគាត់ឲ្យចូលបដិវត្តន៍។ សាក្សីបានសុំទោសដោយនិយាយថា គាត់ភ្លេចអស់ហើយពីរឿងនេះ តែគាត់បានបញ្ជាក់ថា រឿងនេះវាពិតមែន តែកាលនោះគាត់នៅក្មេងពេកដូច្នេះមិនយល់រាក់ជ្រៅពីកិច្ចការលម្អិតរបស់ខ្មែរក្រហមទេ។ ដា លីសាក់ បានឆ្លើយតបថា គាត់មានការភាន់ច្រឡំ ព្រោះកាលនោះសាក្សីមានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧០ពេលដែលគាត់ចូលក្នុងចលនាខ្មែរក្រហម។ ប្រាក់ យុត បានបញ្ជាក់ថា កាលនោះគាត់មិនដឹងថាគាត់មានអាយុប៉ុន្មានទេ ហើយគាត់ក៏មិនដឹងរឿងអ្វីទៀតដែរ ពេលដែលគាត់ចូលរួមក្នុងចលនាខ្មែរក្រហមនោះ។

ដា លីសាក់ បានដូរសំណួរទៅនឹងប្រធានបទអំពីគោលនយោបាយសាសនារបស់ខ្មែរក្រហមដោយសួរទៅសាក្សីអំពីសៀវភៅមួយដែលគាត់អះអាងនៅក្នុងបទសម្ភាសដោយគាត់និយាយថា គាត់បានទទួលសៀវភៅនោះ ដែលរៀបរាប់អំពីគោលនយោបាយបិទវត្តអារាម។ សាក្សីបានបញ្ជាក់ថា

គាត់បានទទួលសៀវភៅមួយក្បាល តែគាត់មិនដឹងថាតើការបិទវត្តអារាមគឺជារឿងល្អឬអាក្រក់ទេ? សាក្សីបានបញ្ជាក់បន្ថែមថា «បើសិនជាមាននៅក្នុងគោលនយោបាយមែននោះ» នោះគាត់នឹងគោរព ដោយគ្មានបង្វែរបង្អង់អ្វីឡើយ ។

ត្រង់ចំណុចនេះ មុននឹងសម្រាកនៅពេលព្រឹក មេធាវីការពារក្តីរបស់ អៀង សារី បានជំទាស់ ទៅនឹងការប្រើប្រាស់ពាក្យ «សក្ខីកម្ម» របស់ព្រះរាជអាជ្ញាទៅនឹង «បទសម្ភាសន៍» កាលពីលើកមុន ដែលផ្តល់ជូនដោយសាក្សីទៅកាន់អ្នកស៊ើបអង្កេត របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ព្រះរាជអាជ្ញា បានឆ្លើយតបដោយធ្វើការកែតម្រូវការអះអាងរបស់មេធាវីការពារក្តីថា សាក្សីនោះមិនត្រូវតម្រូវឲ្យស្បថទេ ហើយថា មុននឹងការធ្វើសម្ភាសនោះសាក្សីបានស្បថរួចហើយ ។ ដា លីសាក់ បានអះអាងថា ដូច្នេះការជំទាស់ក្នុងការប្រើពាក្យរបស់គ្រប់ភាគីទាំងអស់ គឺ «គ្រាន់តែជាបញ្ហានិយណ្ឌសាស្ត្រប៉ុណ្ណោះ» ។ មេធាវីការពារក្តីបានឆ្លើយតបដោយបញ្ជាក់ថា សាក្សីត្រូវតែស្បថ តែគាត់មិនត្រូវប្រើពាក្យ «សក្ខីកម្ម» ទេ ។

អង្គជំនុំជម្រះមិនបានឆ្លើយតបទៅនឹងការអះអាងនេះទេត្រង់ចំណុចនេះ ហើយបានប្រកាសសម្រាកនៅពេលព្រឹក ។

## នួន ជា និង អៀង សារី សុំចេញពីបន្ទប់សវនាការដូចសព្វដង

មុននឹងអង្គជំនុំជម្រះប្រកាសសម្រាក ក្រុមការពារក្តីរបស់ នួន ជា និង អៀង សារី បានជម្រាបទៅអង្គជំនុំជម្រះថា កូនក្តីរបស់ខ្លួនសុំលះបង់សិទ្ធិក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ និងសុំទៅសម្រាកនៅបន្ទប់រង់ចាំវិញ ដើម្បីតាមដានដំណើរការតាមប្រព័ន្ធសោធទស្សន៍វិញ ។ នួន ជា បានអះអាងថា គាត់មានការហត់នឿយ ហើយ អៀង សារី ត្អូញថា គាត់ «ឈឺខ្នងខ្លាំង» ។ សំណើដែលបានធ្វើជាប្រចាំនេះត្រូវបានយល់ព្រមដោយអង្គជំនុំជម្រះ លុះត្រាណាមានលិខិតជាលក្ខណ៍អក្សរ ។ ក្រោយមកអង្គជំនុំជម្រះប្រកាសសម្រាក ។

## ប្រាក់ យុត ធ្វើសក្ខីកម្មបន្ត

ក្រោយពីសម្រាក អង្គជំនុំជម្រះអះអាងថា រាល់អ្វីដែលបាននិយាយឡើងក្រោមការស្បថនោះត្រូវបានចាត់ទុកថាជា «សក្ខីកម្ម» ហើយក្រោយមក អង្គជំនុំជម្រះបានជំទាស់ទៅនឹងមេធាវីការពារក្តីរបស់ អៀង សារី ។ ចៅក្រម ខាត់ វ៉ាយត៍ បានបញ្ជាក់ឲ្យច្បាស់ថា តាមផ្លូវច្បាប់របស់អង្គជំនុំជម្រះនេះ រាល់ពាក្យពេចន៍ដែលធ្វើឡើងដោយការស្បថ គឺត្រូវបានចាត់ទុកថាជា «សក្ខីកម្ម» ហើយត្រូវបានសួរដោយត្រឹមត្រូវពេលសួរសំណួរ ។

ដា លីសាក់ បានឆាកត្រលប់មកកាន់ប្រធានបទទាក់ទងទៅនឹងសៀវភៅអំពីគោលនយោបាយសាសនាវិញដែលបានលើកយកមកនិយាយមុនពេលសម្រាក ។ សាក្សី ប្រាក់ យុត បានអះអាងថា គាត់មិនចាំទេថា គាត់ទទួលបានសៀវភៅនេះពេលណានោះ ហើយគាត់ក៏មិនចង់ "ប៉ាន់ស្មាន" ពីពេលវេលានៃហេតុការណ៍នោះដែរ ហើយគាត់បានស្នើសុំការណែនាំពីអង្គជំនុំជម្រះ ។ ចៅក្រម និល ណុន បានណែនាំ ប្រាក់ យុត ឲ្យឆ្លើយថា គាត់មិនចាំទេ បើសិនជាមិនអាចនឹកឃើញពីពេលវេលានោះ ។

ដា លីសាក់ បានឆាកទៅសួរពីទស្សនាវដ្ដីទង់បដិវត្តន៍វិញ ។ ប្រាក់ យុត បានឆ្លើយតបវិញថា គាត់មិនរក្សាទុក ហើយក៏មិនសូវដឹងពីការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ព្រោះគាត់មិនចេះអក្សរ ។ គាត់ធ្លាប់ឃើញសៀវភៅទស្សនាវដ្ដីទង់បដិវត្តន៍ តែគាត់មិនដែលបានអានទស្សនាវដ្ដីនោះទេ ។

គាត់ត្រូវបានបញ្ជូនទៅខេត្តកំពង់ចាមក្នុងឆ្នាំ១៩៧៧ ហើយក្រោយមកទៅបាត់ដំបងក្នុងភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៨ ។ នៅពេលដែលគាត់ទៅដល់ភូមិភាគពាយ័ព្យ គាត់ត្រូវបានចាត់តាំងឲ្យទៅចម្ការកប្បាសដើម្បីធ្វើពលកម្មដោយដៃ ហើយគាត់បានបញ្ជាក់ទៀតថា ក្រោយពីប្ដីរបស់គាត់ត្រូវបានចាប់ខ្លួន តាម៉ុក បានដកមុខតំណែងរបស់គាត់ទាំងអស់ ព្រោះគាត់ "លែងទទួលបានការទុកចិត្តទៀតហើយ" ។ គាត់ធ្វើការនៅក្នុងចម្ការកប្បាសអស់រយៈពេលពីរខែ តែការងារត្រូវបញ្ចប់ដោយសារតែតំបន់នោះរងការទម្លាក់គ្រាប់បែក ។

ដា លីសាក់ បានអរគុណដល់ ប្រាក់ យុត ចំពោះសក្ខីកម្មនេះ ហើយបានសួរបន្ថែមទៀតទាក់ទងទៅនឹងពេលដែលគាត់ត្រូវបាន "យកទៅអប់រំ" មុននឹងបញ្ជូនទៅដល់ខេត្តកំពង់ចាម ។ ប្រាក់ យុត បានបញ្ជាក់ថា "ការអប់រំ" នេះគឺជាការប្រជុំអស់រយៈពេលពីរម៉ោងជាមួយប្រធានរបស់គាត់ ឈ្មោះ កង ចាប ពេលនោះ កង ចាប បានប្រាប់គាត់ថា គាត់នឹងត្រូវប្ដូរទីកន្លែង តែគាត់មិនបានប្រាប់ទៅ ប្រាក់ យុត ពីមូលហេតុនៃការផ្លាស់ប្ដូរនេះទេ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរអំពីកិច្ចការរដ្ឋពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងតំបន់ដែលគាត់រស់នៅនិងធ្វើការក្នុងរបបខ្មែរក្រហម ។ សំណួរនោះទាក់ទងទៅនឹងការប្រជុំនិងភាពញឹកញាប់នៃការប្រជុំជាមួយគណៈតំបន់នៅក្នុងតំបន់របស់សាក្សីរស់នៅ ។

នៅពេលសួរថាតើនរណាជាអ្នកមានសិទ្ធិសម្រេចថា "តើត្រូវចាត់វិធានការណ៍បែបណាជាមួយអ្នកដែលមានកំហុស" ប្រាក់ យុត បានឆ្លើយថា គណៈស្រុកត្រូវសួរ "យោបល់" ពីគណៈតំបន់ ហើយគណៈស្រុកមិនមានអំណាចឯករាជ្យក្នុងការសម្រេចថាតើនរណាត្រូវយកទៅអប់រំនោះទេ ។ សាក្សីរូបនេះបានបញ្ជាក់ទៀតថា របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅលេខាតំបន់ ហើយមិន

រាយការណ៍ផ្ទាល់មាត់ទេ ។ ដើម្បីសរសេររបាយការណ៍នោះ គណៈស្រុកមិនរាយការណ៍នៅក្នុងរបាយការណ៍នោះដោយបុគ្គលម្នាក់ៗទេ តែគណៈស្រុកទាំងមូលត្រូវតែឯកភាពគ្នាមុននឹងបញ្ចប់របាយការណ៍នោះ ។ របាយការណ៍ទាំងនោះត្រូវបានបញ្ជូនទៅតំបន់ដោយនិរសា មិនមែនផ្ញើតាមទូរលេខទេ ។

នៅពេលសួរសំណួរបន្តទៀត ប្រាក់ យុត បានជំទាស់ថា គាត់មិនពាក់ព័ន្ធក្នុងការសម្រេចចិត្តក្នុងការ«សម្លាប់»នរណាម្នាក់ទេ ។ សាក្សីបានប្រើពាក្យនេះដោយព្រះរាជអាជ្ញាមិនបានសួរទេ ។ សាក្សីបានបញ្ជាក់ទៀតថា ក្នុងនាមគណៈស្រុកដែលមាន«សមាជិកប្រាំមួយនាក់» គាត់មិនមានសិទ្ធិអំណាចដើម្បីចូលរួមការសម្រេចចិត្តទាក់ទងទៅនឹងការសម្លាប់ទេ ។ អង្គប្រជុំគណៈស្រុកដែលគាត់បានចូលរួមគឺពិភាក្សាភាគច្រើនអំពីប្រធានបទដូចជា ការលើកទំនប់ប្រឡាយ ហើយអង្គប្រជុំនោះធ្វើឡើង រាល់បីខែម្ដងតាមពេលវេលាតម្រូវការ ។

ក្រោយមក សាក្សីត្រូវបានសួរអំពីប្រធានបទនៃរបាយការណ៍ដែលសរសេរដោយគណៈកម្មាធិការស្រុករបស់គាត់ ។ សាក្សីបានផ្ដល់សក្ខីកម្មថា ទាក់ទងទៅនឹងរបាយការណ៍ដែលរំលោភដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា «យើងមិនចង់ឲ្យប្រជាជនស្លាប់ទេ» តែគណៈស្រុកត្រូវរាយការណ៍ទៅតំបន់អំពីការរំលោភ និងកំហុសនានាដែលបានកើតឡើង ។ គណៈស្រុកត្រូវតែរាយការណ៍ទៅតំបន់អំពីកិច្ចការផ្សេងទៀតដូចជាកិច្ចការបង្កបង្កើនផលជាដើម ។ ត្រង់ចំណុចនេះ ចៅក្រម និល ណុន បានជំទាស់ទៅនឹងសំណួរនេះហើយបានប្រកាសសម្រាកអាហារថ្ងៃត្រង់ ។

ក្រោយពីសម្រាកអាហារថ្ងៃត្រង់រួច ព្រះរាជអាជ្ញាបានចាប់ផ្ដើមសួរសំណួរទៅ ប្រាក់ យុត ឡើងវិញដោយងាកទៅសួរអំពីប្រធានបទទាក់ទងទៅនឹងការសរសេររបាយការណ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានបញ្ជាក់ថា គណៈស្រុកត្រូវបានស្នើឲ្យជូនដំណឹងទៅតំបន់តាមរយៈរបាយការណ៍នូវទិដ្ឋភាពទាំងអស់ដែលបានកើតឡើងនៅមូលដ្ឋាន ។ នៅពេលសួរអំពីថាតើមានការរៀបរាប់ពីប្រធានបទជាក់លាក់ណាមួយដូចជាការខ្វះម្ហូបអាហារនៅក្នុងរបាយការណ៍នោះដែរឬទេ ប្រាក់ យុត បានឆ្លើយថា របាយការណ៍នោះមិនបានរៀបរាប់ពីហេតុការណ៍បែបនេះទេ ហើយថា គណៈស្រុកបានស្នើសុំជំនួយ ដើម្បីដោះស្រាយបញ្ហាខ្វះខាតម្ហូបអាហារពីថ្នាក់លើដែរ ។ សាក្សីបានបញ្ជាក់ទៀតថា គណៈស្រុករបស់គាត់បានរាយការណ៍ពីចំនួនអ្នកស្លាប់ និងចំនួនអ្នកជំងឺនៅក្នុងស្រុករបស់គាត់ទៅ«ថ្នាក់លើ»ដែរ ។

ក្រោយមក ព្រះរាជអាជ្ញាបានសួរថាតើកម្មាភិបាលថ្នាក់ស្រុកមានដែលទទួលដំណឹងដែរឬទេមុននឹងមានការចាប់ខ្លួនកម្មាភិបាលតាមមូលដ្ឋាន? ប្រាក់ យុត បានឆ្លើយថា មិនដែលមាននរណាជូនដំណឹងមកគាត់អំពីការចាប់ខ្លួនទេ តែមានគេមកប្រាប់គាត់ផ្ទាល់អំពីប្ដីរបស់គាត់ ព្រមទាំងកម្មាភិបាលពីរ

បីនាក់ទៀតដែលត្រូវបានចាប់ខ្លួនដោយ តាម៉ុក ។ ការប្រាប់នោះគឺបីថ្ងៃមុននឹងប្ដីរបស់គាត់ត្រូវបានចាប់ខ្លួន ។ គាត់មិនដឹងពីមូលហេតុដែលនាំទៅរកការចាប់ខ្លួនប្ដីរបស់គាត់ទេ ហើយគាត់«មិនអាចធ្វើអ្វីបានទាំងអស់» ។ ប្ដីរបស់គាត់គ្រាន់តែជាស្មៀនធម្មតាប៉ុណ្ណោះពេលដែលគាត់ត្រូវបានចាប់ខ្លួន ។ ទោះបីជាគាត់ដឹងមុនថា ប្ដីរបស់គាត់នឹងត្រូវចាប់ខ្លួនក៏ដោយ ក៏គាត់«មិនហ៊ានទៅប្រាប់»ប្ដីគាត់ដែរ ព្រោះតាម៉ុក បានព្រមានថា គាត់ក៏ត្រូវមានបញ្ហាដែរបើសិនជាគាត់ទៅប្រាប់ប្ដីនោះ ។ សាក្សីបានបញ្ជាក់ថាគាត់«នឹងមានរឿងធំ» បើសិនជាគាត់ប្រាប់ប្ដីរបស់គាត់មុនអំពីការចាប់ខ្លួននោះ និងបើសិនជាគាត់រត់គេច ។ ទាក់ទងទៅនឹងការប្រជុំជាមួយកម្មាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ភូមិភាគ ប្រាក់ យុត បានបញ្ជាក់ថា ប្រធានបទអ្វីដែលលើកមកនិយាយគឺ«រាល់បញ្ហាទាំងអស់» ដូចជាលក្ខខណ្ឌការងារ និងការចាត់តាំងក្នុងការធ្វើការងារ ។ គណៈភូមិភាគត្រូវបានជូនដំណឹងពីបញ្ហាទាំងអស់នេះ ហើយនេះជាកិច្ចការរបស់ភូមិភាគក្នុងការដោះស្រាយពីបញ្ហាដែលបានរៀបរាប់នោះ ។ នៅពេលសួរអំពីការបោះឆ្នោតក្នុងឆ្នាំ១៩៧៦ក្នុងខេត្តកំពត ប្រាក់ យុត បានបញ្ជាក់ថា គាត់មិនដឹងពីរឿងនេះទេ ។ ក្រោយមក ប្រាក់ យុត បានបញ្ជាក់ថា គាត់មិនបោះឆ្នោត«សភាប្រជាជន»នៅតំបន់គាត់ទេ ។ បន្ទាប់មក ដា លីសាក់ បានសួរទៅសាក្សីថាតើគាត់ត្រូវបានតែងតាំងចូលនៅក្នុងសភាប្រជាជននោះដោយរបៀបណា? សាក្សីបានឆ្លើយថា គាត់ត្រូវបានជូនដំណឹងពីសេចក្ដីសម្រេចនេះ តែគាត់មិនឆ្លើយសំណួរនេះទេ ។

ព្រះរាជអាជ្ញាបានពន្យល់ថា នួន ជា បានអះអាងថា គាត់មិនដឹងពីបញ្ហាជាច្រើនដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះគាត់រវល់នឹង«កិច្ចការច្បាប់»ក្នុងនាមជាប្រធានសភាប្រជាជនកម្ពុជា ។ ដា លីសាក់ បន្តសួរទៅសាក្សីទៀតថា តើគាត់មានដែលធ្វើការទាក់ទងនឹងកិច្ចការច្បាប់ជាមួយ នួន ជា ដែរឬទេ នៅពេលណាមួយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? ប្រាក់ យុត បានឆ្លើយដោយសាមញ្ញថា «ទេ! ខ្ញុំមិនដឹងទេ» ។ ក្រោយមកព្រះរាជអាជ្ញាបានបន្តសួរទៅកិច្ចប្រជុំសភាឆ្នាំ១៩៧៦ ហើយបានសួរថាតើពេលនោះសាក្សីមានមានចូលរួមប្រជុំនោះដែរឬទេ? សាក្សីបានឆ្លើយថា គាត់មិនចាំថាគាត់នៅទីនោះឬអត់ទេ ។ ពេល ដា លីសាក់ ស្នើឲ្យគាត់ខិតខំនឹកហេតុការណ៍នោះឡើងវិញដោយបង្ហាញរូបថតមួយសន្លឹកដែលបានថតក្នុងអំឡុងពេលប្រជុំនោះ ប្រាក់ យុត បានឆ្លើយថា គាត់មិនចាំទេ ហើយគាត់បានបញ្ជាក់ថា បើសិនជាព្រះរាជអាជ្ញានៅតែថា គាត់បានចូលរួមកិច្ចប្រជុំនោះ គាត់ក៏មិនបដិសេធដែរ តែគាត់មិនចាំពីហេតុការណ៍នោះទេ ។

ដា លីសាក់ បានជម្រិតសួរបន្តទៀតទៅសាក្សីថា តើមានដែលចូលរួមកិច្ចប្រជុំណាមួយអំពីការលាលែងពីតំណែងរបស់ព្រះករុណា ព្រះបាទ នរោត្តម សីហនុ ដែរឬទេ ។ ប្រាក់ យុត បានឆ្លើយថា គាត់មិនចូលរួមកិច្ចប្រជុំបែបនេះទេ ហើយគាត់ក៏មិនដឹងរឿងនេះដែរ ។

នៅពេលសួរអំពីលក្ខខណ្ឌរស់នៅ ប្រាក់ យុត បានអះអាងថា ក្នុងខេត្តកំពត មិនដែលមានការខ្វះខាតម្ហូបអាហារទេ ហើយថា ប្រជាជនអាចដោះស្រាយបញ្ហាខ្វះខាតនេះដោយចែករំលែកគ្នាទៅវិញទៅមក ។ ទាក់ទងទៅនិងសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនទៅខេត្តកំពត ប្រាក់ យុត បានបកស្រាយថា គាត់ដឹងពីហេតុការណ៍នេះ តែគាត់មិនដឹងថានរណាជាអ្នកសម្រេចចិត្តក្នុងការជម្លៀសនេះទេ ។ គាត់មិនដែលបានទទួលការណែនាំណាមួយអំពីការជម្លៀសនេះដែរ ។

ក្រោយមក នៅពេលសួរថាតើក្រោយមកត្រូវចាត់វិធានការណ៍បែបណាជាមួយទាហាន និងអតីតមន្ត្រីរបស់ លន់ នល់ ប្រាក់ យុត បដិសេធមិនឆ្លើយសំណួរនេះទេ។ ឆ្លើយមកវិញ ដា លីសាក់ បានអានផ្នែកមួយនៃអត្ថបទសម្ភាសជាមួយ ប្រាក់ យុត ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលក្នុងនោះសាក្សីបានបញ្ជាក់ថា គាត់ត្រូវបានបញ្ជាឲ្យចាប់ខ្លួនអតីតមន្ត្រីរបស់ លន់ នល់ ដើម្បីយកទៅអប់រំ តែក្រោយមកគាត់មិនដឹងថាមន្ត្រីទាំងនោះត្រូវបានបញ្ជូនទៅទីណាទេ ។ នៅក្នុងអត្ថបទសម្ភាសនោះ ប្រាក់ យុត បានបញ្ជាក់ថា គាត់ត្រូវបានណែនាំដោយលេខាតំបន់ឲ្យចាប់ខ្លួនមន្ត្រី លន់ នល់ ទាំងអស់ ។ មកដល់ចំណុចនេះ អង្គជំនុំជម្រះប្រកាសសម្រាកពេលរសៀល ។

### សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងទៅនឹងវិធានទូទៅ៨៧ ចំពោះបញ្ហាភ័ស្តុតាង

ក្រោយពីសម្រាក អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយដែលបានលើកឡើងកាលពីសប្តាហ៍មុនអំពីការតវ៉ាចំពោះការដាក់បញ្ចូលឯកសារទៅក្នុងអង្គជំនុំជម្រះ ។ ចៅក្រម និល ណុន បានអានវិធានផ្ទៃក្នុង៨៧(៣) របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបញ្ជាក់ថា វិធាននេះតម្រូវថា ឯកសារដែលត្រូវដាក់បញ្ចូលត្រូវតែមានយថាភាព ភាពអាចទុកចិត្តបាន និងមានការពាក់ព័ន្ធទៅនិងប្រធានបទ ។

ក្រោយមក ចៅក្រមបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានត្រួតពិនិត្យមើលឯកសារទាំងអស់រួចហើយ ដូចដែលបានដកស្រង់នៅក្នុងដីការដំណោះស្រាយនេះ ។ ឯកសារទាំងនេះត្រូវបាន “សន្មត់ទុកជាមុនថានឹងអាចដាក់បញ្ចូល” ដោយអង្គជំនុំជម្រះ ហើយឯកសារនោះត្រូវបានដាក់ថា អក្ស “E” ដោយអង្គជំនុំជម្រះ ហើយបានដាក់ចូលក្នុងសំណុំរឿងរួចហើយ ។ ផ្ទុយទៅវិញ ឯកសារដែលបានដាក់បញ្ចូលឯទៀតមិនបានដាក់យោងនៅក្នុងដីការដំណោះស្រាយ និងត្រូវត្រួតពិនិតឲ្យបានម្ចត់ចត់ ។

ក្រោយមក ចៅក្រម និល ណុន បានបញ្ជាក់ថា មិនមានការបែងចែកប្រភេទឯកសារទេ ដូចជា សៀវភៅ ឬអត្ថបទជាដើម អាចនឹងយកចេញទាំងមូលដោយអង្គជំនុំជម្រះ ។ ចៅក្រមបានបន្ថែមទៀតថា ខណៈពេលដែលមានការពេញចិត្តទៅនឹងឯកសារដើមទាំងអស់ជាងឯកសារថតចម្លង ឯកសារថតចម្លងក៏អាចដាក់បញ្ចូលបានដែរ តែត្រូវដាក់បណ្តោះអាសន្ន ។ ចៅក្រម និល ណុន បានណែនាំថា

ឯកសារគួរតែស្នើឲ្យមានការដាក់បញ្ជូនទៅក្នុងសំណុំរឿងតាមពេលសមរម្យណាមួយ តែថាចំណុចនេះក៏អាចបត់បែនតាមកាលៈទេសៈដែរតាមការពិចារណាជាក់ស្តែង ។ ទីបញ្ចប់ អង្គជំនុំជម្រះបានបញ្ជាក់ថាភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្មមិនត្រូវដាក់បញ្ចូលទេ ហើយអង្គជំនុំជម្រះបានប្រកាសថា សេចក្តីសម្រេចក្នុងការជំទាស់ទៅនឹងឯកសារណាមួយអាចធ្វើឡើងនៅពេលក្រោយ ។

***សក្ខីកម្មរបស់លោក ឆាំង យុ និងសាក្សីម្នាក់ទៀតត្រូវបានកំណត់នៅក្នុងកាលវិភាគ***

បន្ទាប់មក ចៅក្រម និល ណុន បានប្រកាសថា ពីរសប្តាហ៍តទៅនេះ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆាំង យុ នឹងចូលមកធ្វើសក្ខីកម្ម ព្រមទាំងសាក្សីម្នាក់ទៀតដែលមិនទាន់ប្រាប់ឈ្មោះទេ ។ បន្ទាប់មក អង្គជំនុំជម្រះណែនាំគ្រប់ភាគីទាំងអស់ឲ្យដាក់សំណើរបស់ខ្លួន ដើម្បីសុំពេលក្នុងការសួរសំណួរទៅលោក ឆាំង យុ និងសាក្សីផ្សេងទៀត ។

ក្រោយពីក្រុមការពារក្តីរបស់ នួន ជា ស្នើសុំបញ្ជាក់ ចៅក្រម និល ណុន បានបញ្ជាក់ថាសប្តាហ៍បន្ទាប់នេះ កម្មវិធីនៅពេលព្រឹកនឹងទុកឲ្យទៅ នួន ជា ដើម្បីធ្វើសក្ខីកម្ម ហើយពេលរសៀលនិងទុកឲ្យទៅសាក្សី ប្រាក់ យុត និង លោក ឆាំង យុ និងសាក្សីជំនាញ “TCE 80” ។

**- ចប់ -**